គ.ជ.អ.ប
NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

JICA

ទីភ្នាក់ងារសហប្រតិបត្តិការ
អន្តរជាតិនៃប្រទេសជប៉ុន

# សៀវភៅណែនាំ
# ស្តីពី
# ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
# រាជធានី ខេត្ត

រៀបរៀងដោយ
ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប
នៃគម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC 2 )

ខែកុម្ភៈ ឆ្នាំ២០១៣

# មាតិកា


ផ្នែកទី១ គោលបំណង និងទម្រង់សៀវភៅណែនាំ ........ 1

ផ្នែកទី២ ដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 2

ជំហានទី១៖ ការរៀបចំគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 2

១.១ ការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ........ 3

១.២ កិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ ........ 3

១.៣ ការពិនិត្យសំណើគម្រោងវិនិយោគ ........ 5

១.៤ កិច្ចប្រជុំពិនិត្យតារាងបូកសរុបសំណើគម្រោងវិនិយោគ ........ 6

ជំហានទី២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 8

២.១ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 8

២.២ កិច្ចប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 9

២.៣ សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 10

២.៤ ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគរាជធានី ខេត្ត ........ 11

២.៥ ការរៀបចំក្របខ័ណ្ឌការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ 12

២.៦ ការរៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 13

២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 14

២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 15

ជំហានទី៣៖ ការអនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 15

៣.១ ការអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 16

៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ........ 18

ផ្នែកទី៣ ទម្រង់សៀវភៅ និងសេចក្តីពន្យល់ពីខ្លឹមសារសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 19

៣.១. ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 19

៣.២. សេចក្តីពន្យល់ពីខ្លឹមសារសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 20

ឧបសម្ព័ន្ធ ........ 26

ឧបសម្ព័ន្ធ ១៖ របៀបវារៈការងារសម្រាប់រៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 27

ឧបសម្ព័ន្ធ ២៖ ឧបករណ៍វិភាគ ........ 28

ឧបសម្ព័ន្ធ ២.១ ការគណនាតម្លៃសរុបគម្រោង ........ 28

ឧបសម្ព័ន្ធ ២.២ ការកំណត់ ពិនិត្យ និងជ្រើសរើស ........ 28

ឧបសម្ព័ន្ធ ២.២.១ ការកំណត់គម្រោងដោយផ្អែកលើគោលបំណង គោលដៅ និងដំណោះស្រាយដែលបានព្រមព្រៀង ........ 29
ឧបសម្ព័ន្ធ ២.២.២ វិធីសាស្ត្រផេអូហ្វម៉ាទ្រីស (Pay-off Matrix) ........ 30
ឧបសម្ព័ន្ធ ២.២.៣ វិធីសាស្ត្រដាក់ពិន្ទុ ........ 32
ឧបសម្ព័ន្ធ៣៖ តារាងគំរូនានា ........ 35
ឧបសម្ព័ន្ធ ៣-១៖ តារាង ១.១ សំណើគម្រោងវិនិយោគ ........ 35
ឧបសម្ព័ន្ធ ៣-២៖ តារាង ១.២ក គម្រោងវិនិយោគដែលប្រើប្រាស់ថវិការាជធានី ខេត្ត (គម្រោងវិនិយោគកំពុងដំណើរការ) ........ 36
ឧបសម្ព័ន្ធ ៣-៣៖ តារាង ១.២ខ គម្រោងវិនិយោគដែលប្រើប្រាស់ថវិការាជធានី ខេត្ត (គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ) ........ 37
ឧបសម្ព័ន្ធ ៣-៤៖ តារាង ១.៣ក គម្រោងគាំទ្រដោយក្រសួង ស្ថាប័ន និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត (គម្រោងវិនិយោគកំពុងដំណើរការ) ........ 38
ឧបសម្ព័ន្ធ ៣-៥៖ តារាង ១.៣ខ គម្រោងគាំទ្រដោយក្រសួង ស្ថាប័ន និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត (គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ) ........ 39
ឧបសម្ព័ន្ធ ៣-៦៖ តារាង ១.៤ តារាងបូកសរុបសំណើគម្រោងវិនិយោគរាជធានី ខេត្ត ........ 40
ឧបសម្ព័ន្ធ ៣-៧៖ តារាង ១.៥ តារាងគម្រោងអាទិភាពរបស់រាជធានី ខេត្ត ........ 41
ឧបសម្ព័ន្ធ ៣-៨៖ តារាង ២.១ក គម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (គម្រោងវិនិយោគកំពុងដំណើរការ) ........ 42
ឧបសម្ព័ន្ធ ៣-៩៖ តារាង ២.១ខ គម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ) ........ 43
ឧបសម្ព័ន្ធ ៣-១០៖ តារាង ២.១គ គម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (គម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ) ........ 44
ឧបសម្ព័ន្ធ ៣-១១៖ តារាង ២.១ឃ គម្រោងវិនិយោគដែលប្រើប្រាស់ថវិកាសង្កាត់ក្នុងរាជធានី ........ 45
ឧបសម្ព័ន្ធ ៣-១២៖ តារាង ២.២ មូលនិធិគាំទ្រតាមប្រភព ........ 48
ឧបសម្ព័ន្ធ ៣-១៣៖ តារាង ២.៣ ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងវិនិយោគរាជធានី ខេត្ត .. 49
ឧបសម្ព័ន្ធ ៣-១៤៖ តារាង ៣ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ 50
ឧបសម្ព័ន្ធ ៤៖ សេចក្តីណែនាំបច្ចេកទេសស្តីពីកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ........ 51

# ផ្នែកទី១
# គោលបំណង និងទម្រង់សៀវភៅណែនាំ

សៀវភៅណែនាំនេះរៀបចំឡើងក្នុងគោលបំណងជួយរដ្ឋបាលរាជធានី ខេត្ត ដើម្បី៖

- ស្វែងយល់កាន់តែប្រសើរឡើងពីខ្លឹមសារនៃសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (CPIP) និង
- រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិដោយមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធផ្សេងៗនៅក្នុងរាជធានី ខេត្ត។

សៀវភៅណែនាំនេះ នឹងត្រូវប្រើប្រាស់ដោយក្រុមប្រឹក្សា គណៈអភិបាល ក្រុមការងារកសាងផែនការរាជធានី ខេត្ត មន្ទីរពាក់ព័ន្ធ ទីចាត់ការនានាចំណុះសាលារាជធានី ខេត្ត សង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗទៀតដែលទាក់ទងនឹងការអភិវឌ្ឍក្នុងរាជធានី ខេត្ត។

ទម្រង់សៀវភៅណែនាំនេះចែកចេញជាផ្នែកដូចខាងក្រោម៖

- ផ្នែកទី១៖គោលបំណង និងទម្រង់សៀវភៅណែនាំ
- ផ្នែកទី២៖ដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ផ្នែកទី៣៖ទម្រង់សៀវភៅ និងសេចក្តីពន្យល់ពីខ្លឹមសារសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ឧបសម្ព័ន្ធ៖ ពន្យល់ពីឧបករណ៍វិភាគដើម្បីប្រើប្រាស់ក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត និងតារាងគំរូ ។

# ផ្នែកទី២
# ដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ផ្នែកនេះ បរិយាយពីសេចក្តីសង្ខេបស្តីពីដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលរួមបញ្ចូលទាំងការងារផ្នែករដ្ឋបាល ។

ដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ចែកចេញជា៣ជំហានដូចខាងក្រោម៖

| |
|---|
| ជំហានទី១ ៖ ការរៀបចំគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ជំហានទី៣ ៖ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |

## ជំហានទី១÷ ការរៀបចំគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

**គោលបំណង**

- ដើម្បីរៀបចំបញ្ជីគម្រោងអាទិភាពរាជធានី ខេត្ត សម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលមានសង្គតិភាពជាមួយនឹងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត។

**លទ្ធផលរំពឹងទុក**

- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយគេ
- តារាងបូកសរុបសំណើគម្រោងវិនិយោគ
- តារាងគម្រោងវិនិយោគប្រើប្រាស់មូលនិធិរាជធានី ខេត្ត (គម្រោងវិនិយោគដែលកំពុងដំណើរការ/គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ)
- តារាងគម្រោងវិនិយោគប្រើប្រាស់មូលនិធិរបស់បណ្តាក្រសួង ស្ថាប័ន និងទីភ្នាក់ងារផ្សេងៗ (គម្រោងវិនិយោគដែលកំពុងដំណើរការ/គម្រោងវិនិយោគដែលមានការសន្យារគាំទ្រ)

**ដំណើរការ**

ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ត្រូវធ្វើឡើងដោយផ្អែកលើក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត នៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សា រាជធានី ខេត្ត។

ជំហានទី១ បែងចែកជា៤សកម្មភាពដូចខាងក្រោម៖

| | |
|---|---|
| ១.១ | ការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច |
| ១.២ | កិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ |
| ១.៣ | ការពិនិត្យសំណើគម្រោងវិនិយោគ |
| ១.៤ | កិច្ចប្រជុំពិនិត្យតារាងបូកសរុបសំណើគម្រោងវិនិយោគ |

**១.១ ការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**

**ក) គោលបំណង**

- ដើម្បីរៀបចំតារាងទិន្នន័យសង្ខេបស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចបច្ចុប្បន្ន ព្រមទាំងបញ្ហាប្រឈមនានា នៅក្នុងរាជធានី ខេត្ត។

**ខ) លទ្ធផលរំពឹងទុក**

- ព័ត៌មានសង្ខេបស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចថ្មីៗបំផុត

**គ) សមាសភាពចូលរួម**

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

**ឃ) កិច្ចការដែលត្រូវធ្វើ**

ក្រុមការងារកសាងផែនការរៀបចំសេចក្តីសង្ខេបស្តីពីទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច និងបញ្ហាប្រឈមនានារបស់រាជធានីខេត្ត។

*សម្គាល់៖ សម្រាប់ឆ្នាំទី១នៃអាណត្តិរបស់ក្រុមប្រឹក្សា សូមប្រើ "ព័ត៌មានសង្ខេបស្តីពីស្ថានភាពរបស់រាជធានី ខេត្ត"នៅក្នុងសៀវភៅផែនការអភិវឌ្ឍន៍រាជធានី នៃអាណត្តិរបស់ក្រុមប្រឹក្សា ដូច្នេះសកម្មភាពនេះ អាចរំលងចោលបាន។ ព័ត៌មានសង្ខេបទាំងអស់នេះ ត្រូវធ្វើបច្ចុប្បន្នភាពចាប់ពីឆ្នាំទី២នៃអាណត្តិ របស់ក្រុមប្រឹក្សាតទៅ ដើម្បីឆ្លុះបញ្ចាំងអំពីការប្រែប្រួលគួរកត់សម្គាល់នានានៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច។ **(សូមមើល "សកម្មភាព១.១ ការរៀបចំឯកសារ និងព័ត៌មាន" នៅក្នុងសៀវភៅណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត)**។*

**១.២ កិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ**

**ក) គោលបំណង**

- ដើម្បីរៀបចំតារាងសំណើគម្រោងវិនិយោគ តារាងគម្រោងវិនិយោគដែលកំពុងដំណើរការ និងតារាងគម្រោងវិនិយោគមានការសន្យាគាំទ្រ។

**ខ) លទ្ធផលរំពឹងទុក**

- តារាងសំណើគម្រោង(តារាង១.១)
- តារាងគម្រោងវិនិយោគដែលប្រើប្រាស់ថវិការាជធានី ខេត្ត (គម្រោងវិនិយោគកំពុងដំណើរការ) (តារាង ១.២ក)
- តារាងគម្រោងវិនិយោគដែលប្រើប្រាស់ថវិការាជធានី ខេត្ត (គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ) (តារាង១.២ខ)
- តារាងគម្រោងគាំទ្រដោយក្រសួង ស្ថាប័ន និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត (គម្រោងវិនិយោគកំពុងដំណើរការ) (តារាង ១.៣ក)
- គម្រោងគាំទ្រដោយក្រសួង ស្ថាប័ន និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត (គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ)(តារាង១.៣ខ)

គ) សមាសភាពចូលរួម

- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការ
- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្ត
- តំណាងអង្គការសង្គមស៊ីវិលនានាក្នុងរាជធានី ខេត្ត
- តំណាងវិស័យឯកជនក្នុងរាជធានីខេត្ត
- តំណាងបណ្តាមន្ទីរ និងអង្គភាពនានាក្នុងរាជធានី ខេត្ត។

ឃ) កិច្ចការដែលត្រូវធ្វើ

១. គណៈអភិបាល និងក្រុមការងារកសាងផែនការ រៀបចំ និងចាត់ចែងកិច្ចប្រជុំណែនាំ ដើម្បីណែនាំអំពីការកំណត់ និងរៀបចំបញ្ជីសំណើគម្រោងវិនិយោគសំខាន់ៗ ដែលមិនទាន់មានការសន្យាផ្តល់មូលនិធិ។

២. ក្រុមការងារកសាងផែនការត្រូវណែនាំអំពី៖

- របៀបរៀបចំតារាងសំណើគម្រោងវិនិយោគ និងរបៀបបំពេញតារាងនានា
- លក្ខណៈវិនិច្ឆ័យក្នុងការរៀបចំសំណើគម្រោងវិនិយោគ (សូមមើលតារាងខាងក្រោម៖ **លក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជាបឋមលើសំណើគម្រោង**)
- វិធីសាស្ត្រជ្រើសរើសគម្រោងអាទិភាព (ឧទាហរណ៍៖ ការឆ្លើយតបទៅនឹងគោលបំណង និងគោលដៅអភិវឌ្ឍន៍របស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត)
- ការកំណត់អតិបរមាលើចំនួនគម្រោង និងតម្លៃសរុបរបស់គម្រោង
- កាលបរិច្ឆេទសម្រាប់បញ្ជូនសំណើគម្រោង មកឱ្យក្រុមការងារផែនការរាជធានី ខេត្ត។

**លក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជាបឋមលើសំណើគម្រោង**

| លក្ខណៈវិនិច្ឆ័យ | បរិយាយ |
|---|---|
| ឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត | គម្រោង ឬសេវាដែលឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត តម្រូវការអាទិភាពរាជធានី ខេត្ត និងផែនការតាមវិស័យ។ |
| ស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត | គម្រោង ឬសេវាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត (គម្រោង ឬសេវាដែលជាមុខងារកាតព្វកិច្ច ឬមុខងារជាជម្រើសរបស់រាជធានី ខេត្ត)។ |
| ស្ថិតក្នុងអន្តររដ្ឋបាលដែនដី | គម្រោង ឬសេវាដែលមានលក្ខណៈអន្តរក្រុង ស្រុក ខណ្ឌ |
| កំណត់អតិបរមាលើចំនួនគម្រោង | ត្រូវកំណត់យកគម្រោងតាមចំនួនដែលបានកំណត់ ករណីដែលមានស្នើលើសពីការកំណត់។ |

៣. អ្នកពាក់ព័ន្ធនានាដូចជា អង្គការសង្គមស៊ីវិល និងវិស័យឯកជនរៀបចំតារាងសំណើគម្រោង (សូមមើល **ឧបសម្ព័ន្ធ ៣.១៖ តារាង១.១ សំណើគម្រោង**)។ ឧបករណ៍វិភាគ ដើម្បីកំណត់ចំនួនគម្រោងឱ្យបានសមស្រប សម្រាប់តារាងសំណើគម្រោងត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធខាងក្រោម (សូមមើល**ឧបសម្ព័ន្ធ ២.២.២ វិធីសាស្ត្រផេអូហ្វម៉ាទ្រីស (Pay off Matrix)**)។ ក្រៅពីនេះ ទីចាត់ការផែនការ និងវិនិយោគនៃសាលា

រាជធានី ខេត្តត្រូវបំពេញតារាង គម្រោងវិនិយោគដែលកំពុងដំណើរការ (តារាង១.២ក) និងតារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ (តារាង១.២ខ) (សូមមើល**ឧបសម្ព័ន្ធ ៣.២ និង៣.៣៖ តារាង១.២ក, ១.២ខ គម្រោងវិនិយោគរាជធានី ខេត្ត ដែលប្រើប្រាស់ថវិការបស់រាជធានី ខេត្ត**) ហើយបណ្ដា មន្ទីរ/អង្គភាពនានា និងទីភ្នាក់ងារ ផ្សេងៗទៀតរៀបចំតារាងគម្រោង វិនិយោគដែលមានការ សន្យាគាំទ្រ (តារាង១.៣ក) និងតារាង គម្រោងវិនិយោគដែលកំពុងដំណើរការ(តារាង ១.៣ខ) (សូមមើល**ឧបសម្ព័ន្ធ ៣.៤ និង៣.៥៖ តារាង ១.៣ក, ១.៣ខ គម្រោងវិនិយោគរាជធានី ខេត្ត ដែលប្រើប្រាស់មូលនិធិរបស់ក្រសួង ស្ថាប័ន និងទីភ្នាក់ងារ ផ្សេងៗ**)។

*សម្គាល់៖ រាជធានី ខេត្ត ក៏អាចអញ្ជើញអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនឱ្យរៀបចំតារាងគម្រោងវិនិ យោគដែលមានការសន្យាគាំទ្រ និងគម្រោងវិនិយោគដែលកំពុងដំណើរការទៅតាមទម្រង់របស់ តារាង១.៣ក និងតារាង១.៣ខ។*

៤. អ្នកពាក់ព័ន្ធបញ្ជូនតារាងដែលបានបំពេញរួចមកឱ្យក្រុមការងារកសាងផែនការវិញ។

**១.៣ ការពិនិត្យសំណើគម្រោងវិនិយោគ**

**ក) គោលបំណង**

- ដើម្បីពិនិត្យតារាងសំណើគម្រោងដែលត្រូវបានរៀបចំដោយអ្នកពាក់ព័ន្ធ និងដើម្បីរៀបចំតារាងបូកសរុបសំណើគម្រោង។

**ខ) លទ្ធផលរំពឹងទុក**

- តារាងបូកសរុបសំណើគម្រោងដែលមានការចាត់អាទិភាព

**គ) សមាសភាពចូលរួម**

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. ក្រុមការងារកសាងផែនការ ផ្ទៀងផ្ទាត់តារាងសំណើគម្រោងវិនិយោគដែលអ្នកពាក់ព័ន្ធបានបញ្ជូនមកដោយពិនិត្យលើ៖

- ភាពគ្រប់គ្រាន់ និងច្បាស់លាស់នៃព័ត៌មានក្នុងតារាងទាំងនោះ និង
- ភាពសមស្របនឹងលក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជាបឋមលើសំណើគម្រោង (សូមមើលសកម្មភាព ១.២)។

*សម្គាល់៖*

- *ករណីសំណើគម្រោងមួយចំនួន ពុំមានលក្ខណៈសមស្របសម្រាប់តួនាទីរបស់រាជធានី ខេត្ត តែមានលក្ខណៈសមស្របសម្រាប់តួនាទីរបស់ក្រសួង និងស្ថាប័ន នោះរាជធានី ខេត្ត ត្រូវរៀបចំសំណើគម្រោងទាំងនេះទុកក្នុងបញ្ជីមួយឡែក ដើម្បីស្នើទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។*
- *ករណីសំណើគម្រោងមួយចំនួន ពុំមានលក្ខណៈសមស្របសម្រាប់តួនាទីរបស់រាជធានី ខេត្ត តែមានលក្ខណៈសមស្របសម្រាប់តួនាទីរបស់ក្រុង ស្រុក ខណ្ឌ នោះរាជធានី ខេត្ត ត្រូវរៀបចំសំណើគម្រោងទាំងនេះទុកក្នុងបញ្ជីមួយឡែក ដើម្បីបញ្ជូនទៅក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ។*
- *ក្រុមការងារកសាងផែនការ ត្រូវដកចេញនូវសំណើគម្រោងណា ដែលមានលក្ខណៈមិនសមស្របនឹងលក្ខណៈវិនិច្ឆ័យរបស់សំណើគម្រោងវិនិយោគ។*

២. ប្រសិនបើចាំបាច់ ក្រុមការងារកសាងផែនការ គួរពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីបញ្ជាក់ និងកែសម្រួលព័ត៌មានក្នុងតារាងសំណើគម្រោងវិនិយោគ។ ក្រុមការងារកសាងផែនការ ក៏ត្រូវផ្ទៀងផ្ទាត់ផងដែរថា តើមានគម្រោងដូចគ្នា ឬស្រដៀងគ្នានៅក្នុងចំណោមតារាងសំណើគម្រោងទាំងនេះដែរ ឬទេ។ គម្រោងដូចគ្នា ឬស្រដៀងគ្នាទាំងនេះត្រូវបញ្ចូលគ្នាទៅជាគម្រោងតែមួយ នៅពេលដែលគម្រោងនីមួយៗត្រូវបានបញ្ចូលទៅក្នុងតារាសរុបរួមមួយនៅចុងបញ្ចប់នៃសកម្មភាពនេះ។
*សម្គាល់៖ នៅពេលគម្រោងមួយចំនួនដែលស្ថិតនៅក្នុងផ្នែកដូចគ្នាមានគោលដៅ និងជាតុចេញដូចគ្នា ឬស្រដៀងគ្នា គម្រោងទាំងនេះអាចត្រូវចាត់ទុកថា ជាគម្រោងដូចគ្នា។*

៣. ប្រសិនបើគម្រោងដែលអ្នកពាក់ព័ន្ធនានាបានបញ្ជូនមក មិនឆ្លើយតបនឹងដំណោះស្រាយ និងគោលដៅដែលបានកំណត់ក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ នោះក្រុមការងារកសាងផែនការត្រូវសហការជាមួយរដ្ឋបាលរាជធានី ខេត្ត និងទីភ្នាក់ងារពាក់ព័ន្ធនានា ដើម្បីព្យាយាមបង្កើតគម្រោងដែលជាប់ពាក់ព័ន្ធជាមួយគោលដៅ និងដំណោះស្រាយដែលបានកំណត់ក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍។

៤. ក្រុមការងារកសាងផែនការត្រូវរៀបចំតារាងបូកសរុបសំណើគម្រោងវិនិយោគ (តារាង១.៤) (សូមមើល**ឧបសម្ព័ន្ធ៣.៦៖ តារាង១.៤ តារាងបូកសរុបសំណើគម្រោងវិនិយោគរាជធានី ខេត្ត**) ពីតារាងសំណើគម្រោងវិនិយោគ និងតារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ពីឆ្នាំមុន។

៥. ក្រុមការងារកសាងផែនការ ពិនិត្យ ពិភាក្សា និងចាត់អាទិភាពគម្រោង (ខ្ពស់ មធ្យម ទាប) ក្នុងតារាងបូកសរុបសំណើគម្រោងវិនិយោគ ដោយប្រើវិធីសាស្ត្រដាក់ពិន្ទុ (សូមមើល **ឧបសម្ព័ន្ធ២.២.៣. វិធីសាស្ត្រដាក់ពិន្ទុ**) ឬប្រើវិធីសាស្ត្រផ្សេងទៀត។

### ១.៤ កិច្ចប្រជុំពិនិត្យតារាងបូកសរុបសំណើគម្រោងវិនិយោគ

**ក) គោលបំណង**

- ដើម្បីផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធទាំងអស់ ពិនិត្យ ពិភាក្សា ផ្តល់មតិយោបល់ និងឯកភាពលើតារាងបូកសរុបគម្រោងវិនិយោគ

**ខ) លទ្ធផលរំពឹងទុក**

- តារាងគម្រោងអាទិភាពរបស់រាជធានី ខេត្ត (តារាង ១.៥)

**គ) សមាសភាពចូលរួម**

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- តំណាងគណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមាររាជធានី ខេត្ត
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- អ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចរបស់អភិបាលរាជធានី ខេត្ត។

*សម្គាល់៖ យ៉ាងហោចណាស់ក៏គួរអញ្ជើញតំណាងមកពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនដែលបាន ដាក់សំណើគម្រោងវិនិយោគ គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ គម្រោងវិនិយោគដែលកំពុង ដំណើរការដែរ។*

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. ក្រុមការងារកសាងផែនការធ្វើបទបង្ហាញស្តីពីក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត និងតារាងបូកសរុបសំណើគម្រោងវិនិយោគ។

*សម្គាល់៖ ក្រុមការងារកសាងផែនការត្រូវស្រង់គម្រោងវិនិយោគចូលទៅក្នុងតារាងបូកសរុបសំណើគម្រោងវិនិយោគតាមលំដាប់នៃអាទិភាព ហើយក្រុមការងារកសាងផែនការត្រូវពន្យល់ពីហេតុផលនៃលំដាប់អាទិភាពនេះ (ខ្ពស់ មធ្យម ទាប)។*

២. អ្នកចូលរួម ពិនិត្យ និងពិភាក្សាលើតារាងបូកសរុបសំណើគម្រោងវិនិយោគ ជាពិសេសពិនិត្យលើ៖

- ភាពសមស្របរបស់គម្រោងនៅក្នុងតារាងបូកសរុបសំណើគម្រោងវិនិយោគជាមួយនឹងគោលបំណង គោលដៅ និងដំណោះស្រាយនៃក្របខ័ណ្ឌអភិវឌ្ឍន៍។
- ថាតើមានគម្រោងដូចគ្នា ឬស្រដៀងគ្នានៅក្នុងតារាងបូកសរុបសំណើរគម្រោងដែរ ឬទេ។
- ភាពសមស្របនៃលំដាប់ថ្នាក់អាទិភាព។

៣. ក្រុមការងារកសាងផែនការត្រូវរៀបចំតារាងសំណើរគម្រោងអាទិភាពរបស់រាជធានី ខេត្ត(តារាង១.៥) (សូមមើល**ឧបសម្ព័ន្ធ ៣.៧៖ តារាង១.៥ តារាងគម្រោងអាទិភាពរបស់រាជធានី ខេត្ត**) ដោយផ្អែកលើការពិភាក្សានៅក្នុងកិច្ចប្រជុំត្រួតពិនិត្យ។

**ជំហានទី២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

គោលបំណង

- ដើម្បីរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

លទ្ធផលរំពឹងទុក

- សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ដំណើរការ

ជំហានទី២ បែងចែកជា ៨ សកម្មភាពដូចខាងក្រោម៖

| | |
|---|---|
| ២.១ | ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ២.២ | កិច្ចប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ២.៣ | សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ២.៤ | ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគរាជធានី ខេត្ត |
| ២.៥ | ការរៀបចំក្រុមខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ |
| ២.៦ | ការរៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ២.៧ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ២.៨ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |

**២.១ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

ក) គោលបំណង

- ដើម្បីរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- តារាងគម្រោងវិនិយោគបីឆ្នាំរាជធានី ខេត្ត (តារាង២.១ក, ២.១ខ, ២.១គ)

គ) សមាសភាពចូលរួម

- ក្រុមការងារកសាងផែនការ

ឃ) កិច្ចការដែលត្រូវធ្វើ

១. ក្រុមការងារកសាងផែនការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលផ្អែកតាមមាតិកា ដូចមានកំណត់នៅក្នុងទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត(សូមមើល **ផ្នែកទី៣៖ ទម្រង់សៀវភៅ និងសេចក្តីពន្យល់អំពីខ្លឹមសារសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**)។

២. ក្នុងករណីចាំបាច់ ក្រុមការងារកសាងផែនការរាជធានី ខេត្តអាចស្នើសុំពិគ្រោះយោបល់ជាមួយអង្គភាពស្ថាប័នពាក់ព័ន្ធ។

៣. ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវរៀបចំតារាងគម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (តារាង ២.១ក, ២.១ខ, ២.១ គ) ដោយត្រូវស្រង់៖

- តារាង ១.២កដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគកំពុងដំណើរការបញ្ចូលទៅក្នុងតារាង ២.១ក (សូមមើល**ឧបសម្ព័ន្ធ ៣.៨៖ តារាង២.១ក គម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (គម្រោងវិនិយោគកំពុងដំណើរការ)**។
- តារាង១.២ខ ដែលពាក់ព័ន្ធនឹងគម្រោងមានការសន្យាគាំទ្របញ្ចូលទៅក្នុងតារាង២.១ខ (សូមមើល**ឧបសម្ព័ន្ធ៣.៩៖ តារាង២.១ខ គម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (គម្រោងវិនិយោគ ដែលមានការសន្យាគាំទ្រ**) ។
- តារាង ១.៥ បញ្ចូលទៅក្នុងតារាង ២.១គ ដោយផ្អែកលើអាទិភាព គឺស្រង់គម្រោងអាទិភាពខ្ពស់បញ្ចូលក្នុងឆ្នាំទី១ មធ្យមបញ្ចូលឆ្នាំទី២ និងទាបបញ្ចូលឆ្នាំទី៣។

៤. ក្រុមការងារកសាងផែនការត្រូវធ្វើការបូកសរុបតារាង១.៣ក និង ១.៣ខ ដែលទទួលបានពីអ្នកពាក់ព័ន្ធចូលទៅក្នុងតារាងមួយ ដោយប្រើប្រាស់ទម្រង់ដូចតារាង១.៣ក និង ១.៣ខ។ តារាងបូកសរុបនេះ ត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃកម្មវិធីវិនិយោគរាជធានី ខេត្ត។

**២.២ កិច្ចប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

ក) គោលបំណង

- ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

គ) សមាសភាពចូលរួម

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- តំណាងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត
- តំណាងគណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារក្នុងរាជធានី ខេត្ត
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្ត
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- តំណាងអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធសំខាន់ៗតាមការសម្រេចរបស់អភិបាលរាជធានី ខេត្ត។

ឃ) កិច្ចការដែលត្រូវធ្វើ

១. ក្រុមការងារកសាងផែនការរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ ពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។

២. ក្រុមការងារកសាងផែនការកែសម្រួលសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដោយផ្អែកលើលទ្ធផលនៃកិច្ចប្រជុំ។

## ២.៣ សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ក) គោលបំណង

- ដើម្បីសម្របសម្រួល និងបន្សុីគ្នារវាងគម្រោងនៃកម្មវិធីវិនិយោគរាជធានី ខេត្ត ជាមួយនឹងគម្រោងនៃកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ។
- ដើម្បីពង្រឹងកិច្ចសហការរវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងភាគីពាក់ព័ន្ធនានា
- ដើម្បីកៀរគរធនធានសម្រាប់គាំទ្រគម្រោងវិនិយោគនានាដែលស្នើឡើងដោយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធផ្សេងៗ
- ដើម្បីពិនិត្យរកមើលគម្រោងដូចគ្នា ឬស្រដៀងគ្នាដែលត្រូវបានរៀបចំដោយអង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា។

ខ) លទ្ធផលរំពឹងទុក

- តារាងគម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (តារាង ២.១ខ និង២.១គ)
  *សម្គាល់៖ តារាង២.១ក ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគកំពុងដំណើរការមិនចាំបាច់កែសម្រួលឡើងវិញនោះទេ។*
- កិច្ចព្រមព្រៀងបណ្តោះអាសន្ន

គ) សមាសភាពចូលរួម

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- តំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- តំណាងគណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- ថ្នាក់ដឹកនាំមន្ទីរ អង្គភាព និងទីចាត់ការនានាក្នុងរាជធានី ខេត្ត
- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្ត
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- តំណាងអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងទៀត។

ឃ) កិច្ចការដែលត្រូវធ្វើ

១. រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្សព្វផ្សាយព័ត៌មានអំពីសិក្ខាសាលាសមាហរណកម្មថ្នាក់រាជធានី ខេត្ត ឱ្យបានទូលំទូលាយ ដើម្បីទាក់ទាញការចូលរួមពីសាធារណជន អង្គការសង្គមស៊ីវិល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងអ្នកពាក់ព័ន្ធដែលមានសក្តានុពលនានា។

២. រដ្ឋបាលរាជធានី ខេត្ត ត្រូវជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តរបស់ខ្លួន ឱ្យបញ្ជូនគម្រោងវិនិយោគក្រុង ស្រុក ខណ្ឌ ដែលមិនទាន់មានការសន្យាគាំទ្រ ( *"តារាង២.១គ"* ដែលត្រូវបានបង្កើតនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល) មករាជធានី ខេត្ត សម្រាប់រៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគរាជធានី ខេត្ត។

៣. ក្រុមការងារកសាងផែនការរាជធានី ខេត្ត ពិនិត្យគម្រោងវិនិយោគមិនទាន់មានការសន្យាគាំទ្រ ដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានដាក់ជូន។ ក្នុងករណីពិនិត្យឃើញថាមានគម្រោង ដែលមានលក្ខណៈស្រដៀងគ្នា ឬដូចគ្នារវាងគម្រោងវិនិយោគរបស់រាជធានី ខេត្ត ជាមួយគម្រោងវិនិយោគក្រុង ស្រុក ខណ្ឌណាមួយ ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវពិគ្រោះ ពិភាក្សាជាមួយក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌនោះ ដើម្បីសម្រេចថា តើគម្រោងនោះ ត្រូវរក្សាទុកក្នុងកម្មវិធីវិនិយោគរាជធានី ខេត្ត ឬរក្សាទុកនៅក្នុងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ នោះ។

៤. សមាជិកក្រុមការងារកសាងផែនការ ធ្វើបទបង្ហាញអំពីតារាងគម្រោងវិនិយោគបីឆ្នាំរបស់រាជធានី ខេត្ត (គម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ)(តារាង២.១គ)

៥. តំណាងក្រុង ស្រុក ខណ្ឌ ធ្វើបទបង្ហាញអំពីតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្ររបស់ក្រុង ស្រុក ខណ្ឌ ( *"តារាង២.១គ"* នៅក្នុងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ)

៦. អ្នកពាក់ព័ន្ធពិភាក្សាអំពីខ្លឹមសារនៃបទបង្ហាញ។ នៅពេលអ្នកពាក់ព័ន្ធឯកភាពគ្នាគាំទ្រគម្រោងមិនទាន់មានការសន្យាគាំទ្រ ដែលត្រូវបានធ្វើបទបង្ហាញរួច អ្នកពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងបណ្ដោះអាសន្ន។

**២.៤ ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគរាជធានី ខេត្ត**

**ក) គោលបំណង**

- ដើម្បីជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគរាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- បញ្ជីគម្រោងវិនិយោគដែលប្រើប្រាស់ថវិកាវិនិយោគរាជធានី ខេត្ត

**គ) សមាសភាពចូលរួម**

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- ទីចាត់ការហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្ត

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. ក្រុមការងារកសាងផែនការរាជធានី ខេត្ត ពិនិត្យ ពិភាក្សា និងជ្រើសរើសគម្រោងវិនិយោគសម្រាប់ប្រើប្រាស់ថវិការាជធានី ខេត្ត ពីក្នុងចំណោមគម្រោងវិនិយោគបីឆ្នាំរបស់រាជធានី ខេត្ត (គម្រោងមិនទាន់មានការសន្យាគាំទ្រ)(តារាង២.១គ) ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ត្រូវជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ ដោយផ្អែកលើលទ្ធផលនៃការចាត់អាទិភាព (ដែលពាក់ព័ន្ធនឹងមុខងារជាកាតព្វកិច្ច) ។
- ត្រូវជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌ និងមូលនិធិដែលបានមកពីចំណូលនៅមូលដ្ឋាន និងចំណូលផ្សេងៗទៀត ដោយផ្អែកលើលទ្ធផលនៃការចាត់អាទិភាព(ដែលពាក់ព័ន្ធនឹងមុខងារជាជម្រើស)។
- បន្តជ្រើសរើសគម្រោងតាមលំដាប់លំដោយរហូតដល់អស់ថវិកាវិនិយោគដែលរាជធានី ខេត្តមាន។

*សម្គាល់៖ ប្រសិនបើមានការលំបាកក្នុងការជ្រើសរើសគម្រោង ត្រូវប្រើវិធីសាស្ត្រដាក់ពិន្ទុ។ (សូមមើល* ***ឧបសម្ព័ន្ធ ២.២.៣ វិធីសាស្ត្រដាក់ពិន្ទុ****)*

២. ក្រុមការងារកសាងផែនការ ដាក់គម្រោងដែលបានជ្រើសរើសជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់។ បន្ទាប់អភិបាលដាក់គម្រោងដែលខ្លួនសម្រេចជ្រើសរើសយកជូនក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីពិនិត្យ និងអនុម័ត។

## ២.៥ ការរៀបចំក្របខ័ណ្ឌការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ក) គោលបំណង**

- ដើម្បីរៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគរាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**គ) សមាសភាពចូលរួម**

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

**ឃ) កិច្ចការដែលត្រូវធ្វើ**

### ២.៥.១ ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

១.ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជារៀងរាល់ឆ្នាំ លើការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដោយណែនាំអភិបាលរាជធានី ខេត្តឱ្យធ្វើការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរួមទាំងគម្រោង និងសកម្មភាពនានា ដែលអនុវត្ត និងគ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដូចជា៖

- ក្រុមប្រឹក្សាប្រភេទរួមគ្នា
- ក្រុមប្រឹក្សាប្រភេទផ្សេងទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធផ្សេងទៀតដូចជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។

២. ការរៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ត្រូវផ្តោតលើចំណុចសំខាន់ៗ មួយចំនួនដូចខាងក្រោម ៖

- ការរៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង
- ការកំណត់សូចនាករសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង
- ការកំណត់អ្នកទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង
- ការកំណត់វិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង
- ការកំណត់អ្នកចូលរួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង។

### ២.៥.២ នីតិវិធីអនុវត្តផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

#### ២.៥.២.១ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងវិនិយោគ

១. គណៈអភិបាលដោយមានទីចាត់ការផែនការ និងវិនិយោគជាសេនាធិការ ត្រូវធ្វើការតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពគម្រោងនានា ដោយផ្អែកតាមផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

### ២.៥.២.២ របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តគម្រោងវិនិយោគរាជធានី ខេត្ត

១.នៅអំឡុងត្រីមាសទី៤ គណៈអភិបាលរាជធានី ខេត្តដោយមានទីចាត់ការផែនការនិងវិនិយោគជាសេនាធិការ ត្រូវប្រមូលទិន្នន័យដើម្បីបញ្ចូលក្នុងតារាងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (សូមមើល **ឧបសម្ព័ន្ធ៣.១៤៖ តារាង៣ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**) ហើយត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តដោយសហការជាមួយតំណាងមន្ទីរ អង្គភាពនានា និងអ្នកពាក់ព័ន្ធ។

ខ្លឹមសាររបាយការណ៍នេះរួមមាន៖

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម ។

២.គណៈអភិបាលរាជធានី ខេត្តត្រូវពិនិត្យ និងកែសម្រួលសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ បន្ទាប់មកត្រូវដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តដើម្បីពិនិត្យ និងអនុម័ត។

៣.ប្រសិនបើចាំបាច់ ក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យវឌ្ឍនភាពសូចនាករ និងឧបសគ្គនានា ហើយផ្តល់ការណែនាំសំខាន់ៗលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំនេះ។

៤.ប្រសិនបើចាំបាច់ គណៈអភិបាលដោយមានជំនួយការពីទីចាត់ការផែនការ និងវិនិយោគ ប្រមូលទិន្នន័យបន្ថែម ហើយរៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំដែលត្រូវបានកែសម្រួល ដោយសហការជាមួយតំណាងបណ្តាមន្ទីរ និង អង្គភាពនានាក្នុងរាជធានី ខេត្ត។

៥.ក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំ។

៦.ក្រុមប្រឹក្សារាជធានី ខេត្តត្រូវណែនាំដល់គណៈអភិបាល ឱ្យផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តរួចជូនដល់អ្នកពាក់ព័ន្ធនានា ។

៧.គណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តរួច ទៅលេខាធិការដ្ឋាន គ.ជ.អ.ប ។

## ២.៦ ការរៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ក) គោលបំណង

- ដើម្បីរៀបចំតារាងចាំបាច់នានា និងបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- តារាងគម្រោងវិនិយោគបីឆ្នាំរាជធានី ខេត្ត (តារាង២.១ក, ២.១ខ, ២.១គ)
  *សម្គាល់៖ ចំពោះរាជធានី តារាងបូកសរុបគម្រោងកម្មវិធីវិនិយោគបីឆ្នាំ (តារាង២.១ក, ២.១ខ, ២.១គ) ថ្នាក់ខណ្ឌ និងតារាងគម្រោងវិនិយោគប្រើប្រាស់ថវិកាសង្កាត់នៅក្នុងរាជធានី (តារាង២.១ឃ) នៅថ្នាក់សង្កាត់ ត្រូវបញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រាជធានី។*
- តារាងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងវិនិយោគ
- តារាងមូលនិធិគាំទ្រតាមប្រភព
- សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តដែលបានកែសម្រួល

គ) *សមាសភាពចូលរួម*

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ឃ) **កិច្ចការដែលត្រូវធ្វើ**

១.ផ្អែកតាមលទ្ធផលនៃសិក្ខាសាលាសមាហរណកម្ម និងការសម្រេចរបស់ក្រុមប្រឹក្សាលើការប្រើប្រាស់ថវិការាជធានី ខេត្ត ក្រុមការងារកសាងផែនការត្រូវរៀបចំកែសម្រួល តារាងគម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (តារាង២.១ក ២.១ខ ២.១គ)។

*សម្គាល់៖ គម្រោងទាំងឡាយណា ដែលក្រុមប្រឹក្សារាជធានីខេត្តបានអនុម័តឱ្យប្រើប្រាស់មូលនិធិ របស់រាជធានី ខេត្ត ត្រូវលុបចេញពីតារាង ២.១គ ហើយបញ្ចូលទៅក្នុងតារាង២.១ខ វិញ (តារាងគម្រោងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត)។ គម្រោងវិនិយោគទាំងឡាយណា ដែលត្រូវបានគាំទ្រដោយអង្គការសង្គមស៊ីវិល ឬវិស័យឯកជន ត្រូវដកចេញពីតារាង២.១គ ហើយបញ្ចូលទៅក្នុងតារាងបូកសរុបគម្រោងវិនិយោគដែលប្រើប្រាស់មូលនិធិរបស់បណ្តាក្រសួង ស្ថាប័ន និងទីភ្នាក់ងារផ្សេងៗវិញ (គម្រោងដែលមានការសន្យាគាំទ្រ)។*

២.បន្ទាប់ពីរៀបចំកែសម្រួល*គម្រោងវិនិយោគបីឆ្នាំរាជធានី ខេត្ត* (តារាង ២.១ក, ២.១ខ, ២.១គ) ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវរៀបចំតារាងមូលនិធិគាំទ្រតាមប្រភព (សូមមើល **ឧបសម្ព័ន្ធ៣.១២៖ តារាង២.២ មូលនិធិគាំទ្រតាមប្រភព**)។

៣.ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងវិនិយោគដោយសហការជាមួយមន្ទីរ និងអង្គភាពពាក់ព័ន្ធ ក្នុងករណីចាំបាច់។ (សូមមើល**ឧបសម្ព័ន្ធ៣.១៣៖ តារាង២.៣ ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងវិនិយោគរាជធានី ខេត្ត**)។

*សម្គាល់៖ ចំពោះរាជធានី ត្រូវរៀបចំតារាងមួយចំនួនដូចខាងក្រោម៖*

- *ក្រុមការងារកសាងផែនការ ត្រូវស្នើឱ្យខណ្ឌ បញ្ជូនតារាង២.១ក, ២.១ខ និង២.១គ ហើយតារាងទាំងនោះត្រូវបញ្ចូលទៅក្នុងតារាងបីផ្សេងគ្នាដែលប្រើទម្រង់តាមតារាង២.១ក,២.១ខ និង២.១គ។*
- *ក្រុមការងារកសាងផែនការ ត្រូវស្នើសង្កាត់ បញ្ជូនគម្រោងរបស់ខ្លួន (គម្រោងដែលមានការសន្យាគាំទ្រ គម្រោងដែលកំពុងដំណើរការ និងគម្រោងដែលមិនទាន់មានការសន្យាគាំទ្រ) ដោយប្រើប្រាស់ តារាង២.១ឃ (សូមមើល**ឧបសម្ព័ន្ធ ៣.១១៖ តារាង២.១ឃ គម្រោងវិនិយោគដែលប្រើប្រាស់ថវិកាសង្កាត់ក្នុងរាជធានី**)*

៤.ក្រុមការកសាងផែនការ ត្រូវរៀបចំបញ្ចប់សេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដោយផ្អែកតាមមាតិកានៃទម្រង់សៀវភៅ (**ផ្នែក៣៖ ទម្រង់សៀវភៅ និងសេចក្តីពន្យល់ពីខ្លឹមសារ សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**)។

## ២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ក) **គោលបំណង**

- ដើម្បីកែសម្រួលសេចក្តីព្រាងកម្មវិធីវិនិយោគរាជធានី ខេត្តដោយគណៈអភិបាល

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងកម្មវិធីវិនិយោគដែលបានកែសម្រួល

គ) សមាសភាពចូលរួម

- គណៈអភិបាលរាជធានី ខេត្ត

ឃ) កិច្ចការដែលត្រូវធ្វើ

១. បន្ទាប់ពីទទួលបានសេចក្តីព្រាងកម្មវិធីវិនិយោគពីក្រុមការងារកសាងផែនការ គណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល មុននឹងដាក់ជូនគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសពិនិត្យ និងផ្តល់យោបល់។ កិច្ចប្រជុំនេះត្រូវអនុវត្តទៅតាមរបៀបរបបធ្វើការងាររបស់គណៈអភិបាលរាជធានី ខេត្ត ។

២. ក្រុមការងារកសាងផែនការត្រូវធ្វើការកែសម្រួលសេចក្តីព្រាងកម្មវិធីវិនិយោគរាជធានី ខេត្ត បានត្រឹមត្រូវទៅតាមយោបល់របស់គណៈអភិបាលរាជធានី ខេត្ត។

## ២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ក) គោលបំណង

- ដើម្បីកែសម្រួលលើសេចក្តីព្រាងកម្មវិធីវិនិយោគរាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងកម្មវិធីវិនិយោគរាជធានី ខេត្ត

គ) សមាសភាពចូលរួម

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

ឃ) កិច្ចការដែលត្រូវធ្វើ

១. បន្ទាប់ពីទទួលបានសេចក្តីព្រាងកម្មវិធីវិនិយោគពីគណៈអភិបាលរាជធានី ខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងកម្មវិធីវិនិយោគ។

២. នៅពេលទទួលបានយោបល់ពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលរាជធានី ខេត្ត ត្រូវណែនាំក្រុមការងារកសាងផែនការ ធ្វើការកែសម្រួលបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគរាជធានី ខេត្ត បានត្រឹមត្រូវទៅតាមយោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស រួចហើយត្រូវដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័ត។

## ជំហានទី៣៖ ការអនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

គោលបំណង

- ដើម្បីពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលប្រព្រឹត្តទៅដោយមានការចូលរួមមតិជាសាធារណៈ មានតម្លាភាព និងមានទទួលខុសត្រូវរួមគ្នាក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ។

លទ្ធផលរំពឹងទុក

- កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តដែលបានអនុម័ត
- ខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ។

ដំណើរការ

ជំហានទី៣រួមមាន២សកម្មភាព ហើយសកម្មភាព៣.១ មាន៣សកម្មភាពតូចៗ ដូចខាងក្រោម៖

| | |
|---|---|
| ៣.១ | ការអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ៣.១.១ | ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត |
| ៣.១.២ | កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត |
| ៣.១.៣ | ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត |
| ៣.២ | ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |

### ៣.១ ការអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

### ៣.១.១ ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

ក) គោលបំណង

- ដើម្បីត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- របៀបវារៈនៃកិច្ចប្រជុំ
- សេចក្តីថ្លែងហេតុ
- ឯកសារបង្ហាញអំពីសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- លិខិតអញ្ជើញ

គ) សមាសភាពចូលរួម

- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- ទីចាត់ការផែនការ និងវិនិយោគនៃសាលារាជធានី ខេត្ត
- នាយករដ្ឋបាលនៃសាលារាជធានី ខេត្ត
- អ្នកពាក់ព័ន្ធ និងអ្នកសង្កេតការណ៍នានាចូលរួមតាមការអនុញ្ញាតពីប្រធានក្រុមប្រឹក្សារាជធានី ខេត្ត។

ឃ) កិច្ចការដែលត្រូវធ្វើ

- ក្រុមការងារកសាងផែនការដោយមានជំនួយពីទីចាត់ការផែនការនិងវិនិយោគ និងនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត ត្រូវរៀបចំកិច្ចការសំខាន់ៗដូចខាងក្រោម ៖
  - រៀបចំរបៀបវារៈនៃកិច្ចប្រជុំ
  - រៀបចំសេចក្តីថ្លែងហេតុ
  - រៀបចំឯកសារបង្ហាញអំពីសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
  - រៀបចំ និងបញ្ជូនលិខិតអញ្ជើញ ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី

ខេត្ត និងឯកសារពាក់ព័ន្ធផ្សេងៗទៀត(ឯកសារទាំងនេះត្រូវផ្ញើជូនដល់អ្នកពាក់ព័ន្ធនានាបានយ៉ាងតិច៣ថ្ងៃមុនកិច្ចប្រជុំ)

- រៀបចំកិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលរាជធានី ខេត្ត។

### ៣.១.២ កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

**ក) គោលបំណង**

- ដើម្បីពិនិត្យ កែសម្រួល និងអនុម័តលើសេចក្តីព្រាងបញ្ចប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត

**គ) សមាសភាពចូលរួម**

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងៗទៀត។

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. អភិបាលរាជធានី ខេត្តអានសេចក្តីថ្លែងហេតុ និងធ្វើបទបង្ហាញអំពីសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

២. ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

*សម្គាល់៖ កិច្ចប្រជុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ត្រូវដំណើរការតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។*

### ៣.១.៣ ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានីខេត្ត

**ក) កិច្ចការដែលត្រូវធ្វើ**

១. គណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការកែសម្រួលសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្តនូវសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានកែសម្រួលនេះដើម្បីពិនិត្យ។
បន្ទាប់ពីការអនុម័តរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្តត្រូវរៀបចំសេចក្តីសម្រេចស្តីពីការដាក់ប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា។

២. ក្រុមប្រឹក្សារាជធានី ខេត្តអាចកែប្រែផែនការសកម្មភាពការងារ និងថវិកាដែលឆ្លើយតបទៅនឹងសំណើពីគណៈអភិបាលក្នុងដំណើរការអនុវត្តនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលក្នុងករណីចាំបាច់។

### ៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល

#### ៣.២.១ ការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

១. គណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត និងត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត មន្ទីរផែនការរាជធានី ខេត្ត ហើយក្រុមការងារកសាងផែនការផ្ញើទៅក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

#### ៣.២.២ ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

១. ក្រុមប្រឹក្សាត្រូវណែនាំដល់គណៈអភិបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត បានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដទៃទៀត ។

២. ការផ្សព្វផ្សាយអាចធ្វើឡើងតាមរយៈមធ្យោបាយផ្សេងៗមានដូចជាសារព័ត៌មាន កិច្ចប្រជុំផ្សព្វផ្សាយ ក្តារព័ត៌មាន ។ល។

# ផ្នែកទី៣
# ទម្រង់សៀវភៅ និងសេចក្តីពន្យល់ពីខ្លឹមសារសៀវភៅ
# កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ផ្នែកនេះណែនាំអំពីការរៀបចំទម្រង់សៀវភៅ និងខ្លឹមសារសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដោយមានការពន្យល់លម្អិត។

## ៣.១. ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តដែលបានពន្យល់ក្នុងសេចក្តីណែនាំបច្ចេកទេសមានបង្ហាញដូចខាងក្រោម។ កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ត្រូវបញ្ចូលគម្រោងនៃកម្មវិធីវិនិយោគរបស់ខណ្ឌ និង គម្រោងនៃកម្មវិធីវិនិយោគរបស់សង្កាត់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី។

| |
|---|
| សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| **អារម្ភកថា** |
| សេចក្តីផ្តើម |
| ដែនដីរាជធានី ខេត្ត |
| **ជំពូកទី១÷ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច** |
| ១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច |
| ១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម |
| ១.២.១ ស្ថានភាពសេដ្ឋកិច្ច |
| ១.២.២ ស្ថានភាពសង្គមកិច្ច |
| ១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ |
| ១.២.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ |
| **ជំពូកទី២÷ គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត** |
| ២.១ គម្រោងវិនិយោគ |
| ២.២ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម |
| ២.៣ ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងរាជធានី ខេត្ត |
| **ជំពូកទី៣÷ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីវិនិយោគរាជធានី ខេត្ត** |
| **ឧបសម្ព័ន្ធ** |

## ៣.២. សេចក្តីពន្យល់ពីខ្លឹមសារសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ខ្លឹមសារនៃផ្នែកនីមួយៗ នឹងពន្យល់យ៉ាងលម្អិត រួមទាំងការពិពណ៌នាពីវិធីសាស្ត្រដែលត្រូវប្រើប្រាស់។

**សេចក្តីសម្រេចស្តីពីការដាក់ប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល**

បន្ទាប់ពីទំព័រគម្របសៀវភៅ គឺជាសេចក្តីសម្រេចស្តីពីការដាក់ប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ។ ខ្លឹមសារសំខាន់ៗ ដែលត្រូវបញ្ចូលក្នុងសេចក្តីសម្រេចមានដូចជា ៖

ក) ការប្រកាសដាក់ប្រើប្រាស់ជាផ្លូវការនូវកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត និង

ខ) ការណែនាំដល់ គណៈអភិបាលរាជធានី ខេត្ត ក្នុងការផ្សព្វផ្សាយ ការអនុវត្ត និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល។

សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ។

**អារម្ភកថា**

អារម្ភកថា សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តនិងសេចក្តីសង្ឃឹមដែលនឹងទទួលបានការគាំទ្រមូលនិធិពីស្ថាប័នផ្តល់មូលនិធិដែលមានសក្តានុពល។

**សេចក្តីផ្តើម**

សេចក្តីផ្តើមត្រូវពន្យល់ពីគោលបំណងនៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តក្នុងមួយទំព័រ។

**ផែនទីរាជធានី ខេត្ត**

ផែនទីសំខាន់ៗដែលត្រូវបញ្ចូលរួមមានដូចជា៖

១) ផែនទីរដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធ

២) ផែនទីការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ

៣) ផែនទីភាពក្រីក្រ

៤) ផែនទីផ្ទៃដី និងចម្ងាយ ។

ផែនទីទាំងនេះត្រូវយកចេញពីប្រភពថ្មីបំផុតដូចជា៖

- សៀវភៅទិន្នន័យរាជធានី ខេត្ត
- មន្ទីរនិង/ឬ អង្គភាពពាក់ព័ន្ធ

## ជំពូកទី១÷ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

### ១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

សេចក្តីណែនាំបច្ចេកទេស បង្ហាញពីភាពបត់បែនក្នុងការបំពេញ "តារាងសេចក្តីសង្ខេបព័ត៌មានស្ថានភាពរាជធានី ខេត្ត" ។ អ្នកទទួលខុសត្រូវ (ឧទាហរណ៍៖ ក្រុមការងារកសាងផែនការ) ត្រូវបំពេញតារាងដោយប្រើប្រាស់៖

១) ឯកសារព័ត៌មានស្ថានភាពឃុំសង្កាត់ ក្រុងស្រុកខណ្ឌ រាជធានី ខេត្ត (មន្ទីរផែនការ)
២) ទិន្នន័យផ្នែកអប់រំ (មន្ទីរអប់រំ)
៣) ទិន្នន័យផ្នែកសុខភាព (មន្ទីរសុខាភិបាល)
៤) ទិន្នន័យផ្នែកអភិវឌ្ឍន៍ជនបទ (មន្ទីរអភិវឌ្ឍន៍ជនបទ)
៥) ទិន្នន័យផ្នែកឧស្សាហកម្ម (មន្ទីរឧស្សាហកម្ម និងមន្ទីរពាណិជ្ជកម្ម)
៦) ទិន្នន័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
៧) សៀវភៅកម្រងទិន្នន័យស្ថិតិប្រចាំឆ្នាំ (ក្រសួងផែនការ)
៨) សៀវភៅទិន្នន័យរាជធានី ខេត្ត របស់គ.ជ.អ.បចុងក្រោយគេ
៩) គេហទំព័រគ.ជ.អ.ប
១០) ទិន្នន័យពាក់ព័ន្ធផ្សេងទៀត ។

**តារាង៖ ព័ត៌មានសំខាន់ៗក្នុងរាជធានី ខេត្ត**

| បរិយាយ | ឯកតា | ឆ្នាំ២០១៤ |
|---|---|---|
| ផ្ទៃដីរាជធានី ខេត្ត | គ.ម² | |
| ចំនួនក្រុង ស្រុក ខណ្ឌ | ក្រុង ស្រុក ខណ្ឌ | |
| ចំនួនឃុំ សង្កាត់ | ឃុំ សង្កាត់ | |
| ចំនួនភូមិ | ភូមិ | |
| ចំនួនប្រជាជនសរុប | នាក់ | |
| ចំនួនស្ត្រីសរុប | នាក់ | |
| កំណើនប្រជាជនប្រចាំឆ្នាំ | % | |
| ចំនួនគ្រួសារសរុប | គ្រួសារ | |
